# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## របាយការណ៍ស្តីអំពីការរីកចម្រើនរបស់សាលា – ការណែនាំសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ

THE SCHOOL DISTRICT OF PHILADELPHIA

### តើរបាយការណ៍ស្តីអំពីការរីកចម្រើនរបស់សាលា (SPR) ធ្វើអ្វីខ្លះ?

របាយការណ៍ស្តីអំពីការរីកចម្រើនរបស់សាលា (SPR) គឺជាឯកសារដែលរៀបចំឡើងដោយក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ជារៀងរាល់ឆ្នាំ។ ឯកសារនេះផ្តល់ព័ត៌មានអំពីលក្ខណៈដែលសាលារបស់លោកអ្នកអនុវត្តបាននូវផ្នែកដែលសំខាន់ៗបំផុត សម្រាប់ជោគជ័យរបស់សិស្សានុសិស្ស – **ការសម្រេចបាន** និង **ការរីកចម្រើន** នៃការសិក្សា **បរិយាកាស** និង **សុវត្ថិភាព** របស់សាលា ការត្រៀមខ្លួនជាស្រេចសម្រាប់ **មហាវិទ្យាល័យ** និង **អាជីព**។ របាយការណ៍ស្តីអំពីការរីកចម្រើនរបស់សាលា ជួយយើងឲ្យដឹងអំពី៖

- ✓ សាលាណា ខ្លាំងពូកែផ្នែកណាខ្លះ?
- ✓ តើក្មេងសម្រេចបានកម្រិតខ្ពស់ផ្នែកណាខ្លះ?
- ✓ តើផ្នែកណាខ្លះដែលសាលានីមួយៗត្រូវធ្វើការផ្លាស់ប្តូរ ដើម្បីកែលម្អលទ្ធផលនៃការសិក្សារបស់សិស្សានុសិស្ស?

### ប្រភេទសាលា នៃ SPR

សាលាអាចទទួលបានពិន្ទុ ពី 0-១00%។ ដោយយោងទៅលើពិន្ទុសរុបដែលសាលាទទួលបាន សាលាទាំងអស់ត្រូវគេបែងចែកទៅក្នុងប្រភេទណាមួយនៃប្រភេទទាំងបួន៖



ផ្ទើអន្តរាគមន៍
(0-២៤%)



តាមដានមើល
(២៥-៤៩%)



ពង្រឹង
(៥0-៧៤%)



គំរូ
(៧៥-១00%)

**ផ្ទើអន្តរាគមន៍** – ការអប់រំរបស់សាលាទាំងនេះមានកម្រិតទាប ហើយត្រូវមានការផ្លាស់ប្តូរ។ សាលាទាំងនេះត្រូវការ ការយកចិត្តទុកដាក់ និង ជំនួយ ជាបន្ទាន់។

**តាមដានមើល** – សាលាដែលស្ថិតនៅក្នុងប្រភេទនេះ មានការអប់រំល្អចំពោះផ្នែកខ្លះ ប៉ុន្តែសរុបជាទូទៅ សាលាទាំងនេះត្រូវការ ការពិនិត្យតាមដាន និង ជំនួយ ដើម្បីអាចកែលម្អបាន។

**ពង្រឹង** – សាលាទាំងនេះ មានផ្នែកមួយចំនួន ដែលអាចពង្រឹងឲ្យបានខ្លាំងពូកែ ហើយអាចកែលម្អបានកាន់តែប្រសើ ជាមួយនឹងជំនួយចំណុចពិតប្រាកដ

**គំរូ** – សាលាទាំងនេះបានទទួលពិន្ទុខ្ពស់ និង ជាសាលាដ៏ល្អបំផុតនៅក្នុងទីក្រុងនេះ។

ប្រព័ន្ធនៃការដាក់ពិន្ទុនេះអាចប្រើដើម្បីស្វែងយល់ថាតើសាលារបស់លោកអ្នកធ្វើបានល្អកម្រិតណា ចំពោះផ្នែកនីមួយៗ ក៏ដូចជាពិន្ទុនៃ SPR។

## តើសាលារបស់ខ្ញុំទទួលបាន ពិន្ទុ SPR ដោយរបៀបណា?

អ្វីពិតប្រាកដដែលគេរាប់បញ្ចូលពិន្ទុសរុបរបស់សាលា គឺអាស្រ័យទៅលើសិស្សានុសិស្សដែលសាលានេះបង្រៀន។ ឧទាហរណ៍ ពិន្ទុសរុប របស់សាលាបឋមសិក្សា និង អនុវិទ្យាល័យ ផ្អែកទៅលើ **ការសម្រេចបាន ការរីកចម្រើន** និង **ស្ថានភាពរបស់សាលា** ក្នុងខណៈដែល ពិន្ទុរបស់វិទ្យាល័យ ត្រូវរាប់បញ្ចូលការត្រៀមខ្លួនជាស្រេចសម្រាប់ **មហាវិទ្យាល័យ** និង **អាជីព** ផងដែរ។ មុខវិទ្យា ឬ ផ្នែក នីមួយៗរបស់ SPR មានទម្ងន់ខុសៗគ្នាសម្រាប់ពិន្ទុសរុបទាំងអស់។




| | ការសម្រេចបាន | ការរីកចម្រើន | បរិយាកាសសាលា | មហាវិទ្យាល័យ និង អាជីព | |
|---|---|---|---|---|---|
| បឋមសិក្សា មត្តេយ្យ-៨ និង អនុវិទ្យាល័យ | ៣០% | ៤០% | ៣០% | អត់ពាក់ព័ន្ធ | ១០០% |
| វិទ្យាល័យ | ៣០% | ៤០% | ២០% | ១០% | ១០០% |

ពិន្ទុសរុបរបស់សាលាមួយ បង្ហាញឲ្យឃើញថាតើសាលានោះបង្រៀនបានល្អកម្រិតណា បើប្រៀបធៀបទៅនឹងទិសដៅរបស់ក្រសួង ហើយគេអាចប្រើពិន្ទុនេះដើម្បីស្វែងយល់អំពីការប្រែប្រួលនៃការអប់រំ ក្នុងចន្លោះរយៈពេលណាមួយ។

# ស្វែងយល់អំពីផ្នែកផ្សេងៗនៃ SPR

| ការសម្រេចបាន | ការរីកចម្រើន | ស្ថានភាពរបស់សាលា | ត្រៀមសម្រាប់ មហាវិទ្យាល័យ និង អាជីព |
|---|---|---|---|
| ផ្នែកនេះ វាយតម្លៃថាតើសិស្សធ្វើបានល្អកម្រិតណា ចំពោះផ្នែកនៃ ការអាន ការសរសេរ គណិតវិទ្យា និង ចំណេះវិទ្យាសាស្ត្រ ក៏ដូចជាការស្ទាត់ជំនាញរបស់សិស្ស ដែលត្រូវការរៀនភាសាអង់គ្លេស។ | ផ្នែកនេះបង្ហាថា តើសិស្សានុសិស្សបានរៀន តាមកម្រិតនៃអ្វីៗដែលពួកគេត្រូវរៀនពីមួយឆ្នាំទៅមួយឆ្នាំដែរឬទេ ផ្នែក ការអាន/អក្សរសិល្ប៍ គណិតវិទ្យា និង ចំណេះវិទ្យាសាស្ត្រ ហើយបើនៅវិទ្យាល័យ តើសិស្ស អាចប្រឡងចេញទាន់ពេលវេលាដែរឬទេ។ | សាលាគប្បីជាទីកន្លែងដែលមានសុវត្ថិភាព និងទាក់ទាញសិស្សឲ្យចង់មករៀន។ ផ្នែកនេះវាយតម្លៃវត្តមានអវត្តមាន ការចូលរួមរបស់សិស្ស និង លទ្ធផលពីរបាយការណ៍នៃការស្ទង់មតិប្រចាំឆ្នាំ។ | ផ្នែកនេះបង្ហាញថា តើសិស្សនៅវិទ្យាល័យប្រឡងចេញដែរឬអត់ ហើយតើពួកគេបានត្រៀមខ្លួនសម្រាប់ បន្តការសិក្សារបស់ពួកគេនៅមហាវិទ្យាល័យ និង សម្រាប់ទិសដៅសម្រាប់អាជីព ដែរឬអត់ (សម្រាប់តែសិស្សវិទ្យាល័យ) |
| **តើ SPR ពិនិត្យមើលទិន្នន័យអ្វីខ្លះ?** | | | |
| ✓ **ការស្ទាត់ជំនាញនៃពិន្ទុប្រឡង PSSA/Keystone**<br>✓ **ការស្ទាត់ជំនាញនៃពិន្ទុប្រឡង ACCESS (សម្រាប់សិស្ស ELLs)**<br>✓ **អានបានតាមកម្រិតថ្នាក់** | ✓ **សន្ទស្សន៍កំណើនមធ្យម (AGI)**<br>✓ **កំណើននៃពិន្ទុប្រឡង ACCESS (សម្រាប់សិស្ស ELLs)**<br>✓ **ភាគរយនៃសិស្សដែលរៀនបានទាន់កម្រិតថ្នាក់**<br>✓ **សមភាព** | ✓ **វត្តមានអវត្តមាន**<br>✓ **ការដាក់វិន័យនៅក្នុងសាលា**<br>✓ **ការបញ្ឈប់បណ្ដោះអាសន្ន**<br>✓ **ការស្ទង់មតិរបស់ សិស្ស និង មាតាបិតា** | ✓ **ការប្រឡងចេញពីវិទ្យាល័យ**<br>✓ **ការចូលរៀននៅមហាវិទ្យាល័យ**<br>✓ **ការត្រៀមខ្លួនសម្រាប់ មហាវិទ្យាល័យ/អាជីព**<br>✓ **ការស្ទង់មតិរបស់សិស្ស** |
| **ហេតុអ្វីបានជាវាមានលក្ខណៈសំខាន់?** | | | |
| ការអានបានតាមកម្រិតថ្នាក់ នឹងនាំឲ្យទទួលបានជោគជ័យនៅក្នុងមុខវិទ្យាដទៃទៀត។<br>ការឆាប់ទទួលបានជោគជ័យរបស់សិស្ស អាចជះឥទ្ធិពលដល់ឱកាសផ្លាស់ប្ដូរសាលា និង ការទទួលឲ្យចូលរៀននៅវិទ្យាល័យ។<br>ពិន្ទុនៃការប្រឡង អាចមានឥទ្ធិពលដល់ការចូលរៀននៅមហាវិទ្យាល័យ (សម្រាប់សិស្សវិទ្យាល័យ) | សម្រាប់សិស្សដែលរៀនមិនទាន់គេ ការរីកចម្រើនខ្លាំងក្លាគឺជាការចាំបាច់ ដើម្បីឲ្យសិស្សរៀនបានទាន់កម្រិតថ្នាក់។<br>នៅវិទ្យាល័យរៀនមិនបានពិន្ទុគ្រប់ចំនួន មានបញ្ហាអាចធ្វើឲ្យសិស្សឈប់មករៀន។ | បរិយាកាសល្អរបស់សាលា គឺជាគ្រឹះនៃការសិក្សារបស់សិស្ស។<br>បើសិស្សមិនមកសាលា ពួកគេមិនអាចសិក្សាបានទេ។<br>មតិរបស់ មាតាបិតា និង សិស្សានុសិស្ស មានសារៈសំខាន់ណាស់សម្រាប់ជោគជ័យរបស់សាលា។ | ការប្រឡងចេញពីវិទ្យាល័យ អាចបង្កើនឱកាសនៅពេលក្រោយសម្រាប់ជីវិតរស់នៅរបស់សិស្ស។<br>ការប្រឡងចេញពីវិទ្យាល័យជួយធ្វើឲ្យទីក្រុងរបស់យើងកាន់តែប្រសើរឡើង។<br>ត្រៀមខ្លួនបានល្អដើម្បីប្រឡងចេញ នឹងអាចធ្វើបានល្អនៅមហាវិទ្យាល័យ/អាជីព។ |
| **តើលោកអ្នកអាចធ្វើអ្វីបាន?** | | | |
| **គាំទ្រការសិក្សារបស់សិស្ស** ក្រោយម៉ោងសិក្សា។<br>**ដឹងថ្ងៃខែប្រឡង** ធ្វើយ៉ាងណាឲ្យសិស្សត្រៀមខ្លួន ហើយលើកទឹកចិត្តឲ្យពួកគេខិតខំឲ្យអស់ពីសមត្ថភាព។<br>**តាមដានការប្រឡង** Benchmarks និងរបាយការណ៍ពិន្ទុ របស់សិស្ស។<br>**ពិភាក្សាអំពីមុខវិជ្ជា**ជាមួយសិស្ស និងគ្រូរបស់ពួកគេ។<br>សហការជាមួយសាលា និង/ឬ **ក្រុមប្រឹក្សាសាលា (SAC)** ដើម្បីបង្កើនជោគជ័យរបស់សិស្ស។ | | **បំពេញការស្ទង់មតិប្រចាំឆ្នាំ** ហើយជំរុញឲ្យសិស្សបំពេញដែរ។<br>ធ្វើយ៉ាងណា**កុំឲ្យសិស្សអវត្តមានលើសពី១ថ្ងៃ ក្នុងមួយខែ** ទោះជា មាន ឬ គ្មាន មូលហេតុ ក៏ដោយ។<br>សហការជាមួយសាលា និង/ឬ **ក្រុមប្រឹក្សាសាលា (SAC)** ដើម្បីកែលម្អបរិយាកាសរបស់សាលា។ | ចុះឈ្មោះសិស្សក្នុង **កម្មវិធីរៀនយកពិន្ទុបន្ថែម ឬកម្មវិធីនៅរដូវក្ដៅ** ដើម្បីរៀនឲ្យទាន់គេ។<br>បង្កើនការចូលរួមក្នុងការសិក្សាបន្ថែម និងកម្មវិធី ដែលអាច **ត្រៀមសិស្សសម្រាប់ មហាវិទ្យាល័យ និង អាជីព។**<br>បញ្ជាក់ពីសារៈសំខាន់នៃ **វត្តមានអវត្តមាន។**<br>ជំរុញសិស្សឲ្យ**បំពេញការស្ទង់មតិប្រចាំឆ្នាំ។** |

## ព័ត៌មានបន្ថែមអំពី SPR

វិបសៃអំពី របាយការណ៍ស្តីអំពីការរីកចម្រើនរបស់សាលា របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា រួមមានជំនួយ និងព័ត៌មានបន្ថែម អំពី SPR និងអ្វីៗដែលរបាយការណ៍នេះស្ទង់មើល៖ **http://www.philasd.org/language/khmer/school-progess-report**.

ក្នុងទំព័រវិបសៃនេះ លោកអ្នកនឹងឃើញ **ការណែនាំអំពីការប្រើ SPR សំណួរដែលគេឧស្សាហ៍សួរ** និង **ការណែនាំអំពី SPR សម្រាប់ មាតាបិតា និង ក្រុមគ្រួសារ (មានជាភាសាផ្សេងៗ)** ព្រមទាំង **ច្បាប់របស់ SPR** ដែលផ្តល់ព័ត៌មានលម្អិតអំពីវិធីគណនាប្រការនីមួយៗនៅក្នុង SPR។

## ការប្រឡង និង ថ្ងៃខែសំខាន់ៗ ផ្សេងទៀត

ពិនិត្យមើលប្រតិទិននៅក្នុងវិបសៃរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឲ្យបានទៀងទាត់ ដើម្បីឲ្យដឹងអំពី **ថ្ងៃខែនៃការប្រឡងក្នុងពេលខាងមុខ ថ្ងៃខែចុះឈ្មោះចូលរៀន** និង **ថ្ងៃខែសំខាន់ៗផ្សេងទៀត** សម្រាប់កូន និងសាលា របស់លោកអ្នក ៖ **www.philasd.org/language/khmer/calendar**

## ការស្ទង់មតិប្រចាំឆ្នាំ

យើងខ្ញុំចង់បានយោបល់ពីលោកអ្នក! **សូមបំពេញការស្ទង់មតិរបស់ មាតាបិតា និង អាណាព្យាបាល ប្រចាំឆ្នាំ** ដើម្បីប្រាប់យើងខ្ញុំឲ្យដឹងអំពីសាលា និងវិធីដែលយើងអាចកែលម្អសាលារបស់លោកអ្នក៖ **http://www.philasd.org/parentsurvey/index.php?lang=km**

ពិនិត្យមើល**លទ្ធផលនៃការស្ទង់មតិរបស់សាលាលោកអ្នក** នៅក្នុងវិបសៃនៃការស្ទង់មតិរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖ **schoolsurveys.philasd.org**.

## ចូលរួម និង ជួយដល់ការកែលម្អសាលា

FACE
OFFICE OF FAMILY AND COMMUNITY ENGAGEMENT
The School District of Philadelphia

សូមមើលវិបសៃរបស់ ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ (FACE) ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី **វិធីជួយ កូន និង សាលា របស់លោកអ្នក ដែលល្អបំផុត៖ http://www.philasd.org/language/khmer/**

សូមចូលរួម! គិតគូរចូលរួមជាមួយ **ក្រុមប្រឹក្សាសាលា (SAC)** ដើម្បីជួយគាំទ្រដល់ជោគជ័យនៃការសិក្សារបស់សិស្ស ការកែលម្អបរិយាកាស និង ទម្លាប់ របស់សាលា និងពង្រឹងការចូលរួមរបស់ក្រុមគ្រួសារ។